ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ...០២២......ន.គ.ស .សរ.ជ.លា

ថ្ងៃច័ន្ទ ៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរំលឹកអំពីការអនុវត្តកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ឱ្យធ្វើសវនកម្មឯករាជ្យ និង ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មឯករាជ្យរួច មកនិយ័តករគណនេយ្យនិងសវនកម្ម

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម អនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងប្រកាសលេខ៥៦៣ សហវ.ប្រក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មឯករាជ្យ **និយ័តករគណនេយ្យនិងសវនកម្ម** នៃ**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** សូមជម្រាបជូន អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាម្ចាស់សហគ្រាសទាំងអស់ មេត្តាជ្រាបថា៖ សហគ្រាសទាំងឡាយណាដែលស្ថិតនៅក្នុង**ចំណុច ១ ដល់ ៤** ខាងក្រោម **មានកាតព្វកិច្ចត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ឱ្យធ្វើសវនកម្មឯករាជ្យជាកំហិត**៖

១. សហគ្រាសសាធារណៈ

២. សហគ្រាសទទួលខុសត្រូវជាសាធារណៈ

៣. គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៤. សហគ្រាសដែលមិនស្ថិតក្នុងចំណុច ១, ២ និង ៣ ខាងលើ ប៉ុន្តែបានបំពេញលក្ខណៈវិនិច្ឆ័យទាំង២ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យចំនួន៣ ខាងក្រោម ត្រូវមានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មឯករាជ្យ៖

**លក្ខណៈវិនិច្ឆ័យ១៖** មានទឹកប្រាក់ផលរបរប្រចាំការិយបរិច្ឆេទគណនេយ្យចាប់ពី ៤.០០០.០០០.០០០(បួនប៊ីលាន) រៀល ឡើងទៅ។

**លក្ខណៈវិនិច្ឆ័យ២៖** មានទ្រព្យសកម្មសរុបចាប់ពី ៣.០០០.០០០.០០០ (បីប៊ីលាន)រៀល ឡើងទៅ គិតត្រឹមថ្ងៃបិទការិយបរិច្ឆេទគណនេយ្យ។

**លក្ខណៈវិនិច្ឆ័យ៣៖** មានចំនួនកម្មករនិយោជិតបម្រើការងារចាប់ពី១០០(មួយរយ)នាក់ ឡើងទៅ ដោយយោងទៅតាមចំនួនកម្មករនិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ។

សហគ្រាសអាចជ្រើសរើសក្រុមហ៊ុនសវនកម្មឯករាជ្យណាមួយដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មនៅមានសុពលភាព ដែលផ្តល់ដោយ **ន.គ.ស.**។

សហគ្រាសត្រូវបញ្ចប់ការងារធ្វើសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ មិនឱ្យហួសរយៈពេល ៦(ប្រាំមួយ)ខែ គិតចាប់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យ និងត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុធ្វើសវនកម្មឯករាជ្យរួចមក **ន.គ.ស.** មិនឱ្យហួសរយៈពេល៦(ប្រាំមួយ)ខែ និង១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ: ០៩៥-២៣ ៨៨២ ១១១
Phone: 023 882 111

សហគ្រាសត្រូវប្រើប្រព័ន្ធអនឡាញ (E-filing system) របស់ **ន.គ.ស.** ដើម្បីដាក់បញ្ជូនរបាយការណ៍-ហិរញ្ញវត្ថុដែលរងសវនកម្មរួចមក **ន.គ.ស.**។ បែបបទ និងនីតិវិធីនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញ (E-filing system) ព្រមទាំងវិធានអនុវត្ត ដែលនឹងត្រូវកំណត់ដោយ **ន.គ.ស.**។

ការមិនបានអនុវត្តកាតព្វកិច្ចនេះ សហគ្រាស នឹងរងទោសទណ្ឌស្របតាម**អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម**។ សហគ្រាសដែលមិនបានបំពេញកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ សម្រាប់ការិយបរិច្ឆេទគណនេយ្យឆ្នាំ២០២០ មក **ន.គ.ស.** និងមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មរួចមក **ន.គ.ស.** ត្រូវរងពិន័យអន្តរការណ៍ ដូចបានកំណត់នៅក្នុង**ចំណុច ឃ** និង **ឆ នៃមាត្រា៤** ឬ **មាត្រា៥** នៃអនុក្រឹត្យ លេខ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងមិនមានការលើកលែង។

**សហគ្រាសដែលនៅតែបន្តមិនអនុវត្តកាតព្វកិច្ចនេះសម្រាប់ការិយបរិច្ឆេទគណនេយ្យឆ្នាំ ២០២១ និងការិយ-បរិច្ឆេទឆ្នាំបន្តបន្ទាប់ ត្រូវបានចាត់ទុកជា "ករណីមិនរាងចាល" និងត្រូវរងនូវពិន័យអន្តរការណ៍ ដូចបានកំណត់នៅក្នុងមាត្រា១១នៃអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម**។

វេទិកាស្តីពីនីតិវិធីនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មរួចមក **ន.គ.ស.** នឹងធ្វើឡើងនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៨:៣០នាទីព្រឹក តាមប្រព័ន្ធអនឡាញ (Zoom)។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈលេខទូរស័ព្ទ និងតេឡេក្រាម÷ ០៧០ ៩២ ៩២ ៣៧ ឬ ០១៦ ៥៩ ៨៣ ៨៦ ឬ០៧៧ ៩៦ ៨៣ ៩៦ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាម្ចាស់សហ-គ្រាស មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយក**

**ប៊ូ ថារិន**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យ
និងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់
និយ័តករគណនេយ្យនិងសវនកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.................... ន.គ.ស .សរ.សំ.ណា

ថ្ងៃចន្ទ ៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

## សេចក្តីជូនដំណឹង

## ស្តីពី

## បច្ចុប្បន្នភាពនៃបញ្ជីក្រុមហ៊ុនដែលទទួលបាននីតិសម្បទាផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ និង សវនកម្ម

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**)មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាសប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា÷ដើម្បីជួយសម្រួលដល់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញក្នុងការជ្រើសរើសក្រុមហ៊ុនគណនេយ្យ ឬ ក្រុមហ៊ុនសវនកម្មសម្រាប់ការផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ ឬ សេវាវិជ្ជាជីវៈសវនកម្ម និយ័តករគណនេយ្យនិងសវនកម្ម សូមផ្តល់ជូននូវបញ្ជីឈ្មោះក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យ និងក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្ម ដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករគណនេយ្យនិងសវនកម្ម មានដូចខាងក្រោម÷

### I. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាអក្សរឡាតាំង | សេចក្តីសម្រេចលេខ | កាលបរិច្ឆេទផុតសុពលភាព |
|---|---|---|---|---|
| ១ | ប្លូ ឆាធើរ អឹខោនថិន អេន អឌីតធ័រ ឯ.ក | Blue Chartered Accountants and Auditors Co., Ltd | ០១៥៨ សសរ ន.គ.ស. | ៣១-កក្កដា-២០២៣ |
| ២ | 3អេស ខនសាល់ធីង ឯ. ក | 3S Consulting Co., Ltd | ០១៦០ សសរ ន.គ.ស. | ៣១-កក្កដា-២០២៣ |
| ៣ | វីឌីប៊ី ឡូយ លីមីធីត | VDB Loi Limited | ០១៥០ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២២ |
| ៤ | អេ-អិចសឹឡិន ខនសាល់ធេនស៊ី ឯ.ក | A-Xcellent Consultancy Co., Ltd | ០០១៤៥ សសរ ក.ជ.គ. | ៣១-តុលា-២០២២ |
| ៥ | ស្កាយ លីមីធីត អឹខោនធីង (ខេមបូឌា)ខូ អិលធីឌី | Sky Limited Accounting (Cambodia) Co., Ltd | ០០១៤៨ សសរ ក.ជ.គ. | ៣០-មិថុនា-២០២២ |
| ៦ | ហាន់ហ្គោ ស៊ូជីតាក់&អឹខោនធីង(ខេមបូឌា) | Hongo Tsuji Tax & Accounting (Cambodia) Co., Ltd | ០១៥១ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៧ | អាយ-គ្លោខល | I-Glocal Co., Ltd | ០០១២៨ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ: ០២៣ ៨៨២ ១១១
Phone: 023 882 111

## II. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាអក្សរឡាតាំង | សេចក្តីសម្រេចលេខ | កាលបរិច្ឆេទផុតសុពលភាព |
|---|---|---|---|---|
| ១ | អ៊ីស្ត វីង អឌីធីង &ខនសាល់ធីង | East Wing Auditing & Consulting Co., Ltd | ០១៥៩ សសរ ន.គ.ស. | ៣១-កក្កដា-២០២៣ |
| ២ | វីប៊ីធី អេន ផាតនើរ ឯ.ក | VBT and Partners Co., Ltd | ០១៥៧ សសរ ន.គ.ស. | ៣១-ឧសភា-២០២៣ |
| ៣ | ទ្រីណីធី ប្រូហ្វេសិនណល ខូ អិលធី ឌី | Trinity Professional Co., Ltd | ០១៥៥ សសរ ន.គ.ស. | ៣០-មេសា-២០២៣ |
| ៤ | អេកូវីសវីអេសឌីខេ & ផាតនើរឯ.ក | ECOVIS VSDK & Partner Co., Ltd | ០១៥៣ សសរ ក.ជ.គ. | ៣១-មីនា-២០២៣ |
| ៥ | ភី អេ ធី ប្រូហ្វេសិនណល លីមីធីត | P A T Professional Limited | ០១៥២ សសរ ក.ជ.គ. | ២៨-កុម្ភៈ-២០២៣ |
| ៦ | ខេម អ៊ីខោនធីង & ថាក់ សឺវីស ឯ.ក | Cam Accounting & Tax Service Co.,Ltd | ០១៥៤ សសរ ក.ជ.គ. | ២៨-កុម្ភៈ-២០២៣ |
| ៧ | អេសអិមគ្លូបិលអ៊ីខោនធីង& ខនសាលធីង | SM Global Accounting & Consulting Co., Ltd | ០០១៥០ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២២ |
| ៨ | អាត្លាស ខនសាល់ធីង ឯ.ក | Atlas Consulting Co., Ltd | ០០១៤៦ សសរ ក.ជ.គ. | ៣១-តុលា-២០២២ |
| ៩ | ផេក ខនសាល់ធីង ឯ.ក | PAC Consulting Company limited | ០០១២៧ សសរ ក.ជ.គ. | ១០-កញ្ញា-២០២២ |
| ១០ | អេធីអេភី &ផាតនើរ ឯ.ក | ATAP & Partners Company Limited | ០០១៣៤ សសរ ក.ជ.គ. | ៣១-សីហា-២០២២ |
| ១១ | ហ្វូរមី & ផាតនើរ ឯ.ក | Fourmi & Partners Co., Ltd | ០០១២៥ សសរ ក.ជ.គ. | ១-សីហា-២០២២ |
| ១២ | រីចស៍ & ផាតនើរ | Reachs & Partners Co., Ltd | ០០៧៥ សសរ ក.ជ.គ. | ៣១-កក្កដា-២០២២ |
| ១៣ | សំរិទ្ធិ អ៊ីខោនធីង អេន មេនេចម៉ិន ឯ.ក | Samrith Accounting and Management Co., Ltd | ០១៥៦ សសរ ន.គ.ស. | ៣១-កក្កដា-២០២២ |
| ១៤ | ហ្វូណន ខនសាល់ធីង ឯ.ក | Funan Consulting Co., Ltd | ០០១០៤ សសរ ក.ជ.គ. | ៩-កក្កដា-២០២២ |
| ១៥ | អេសស៊ីអេសគ្លូបិលខនសាល់ធីង(ខេមបូឌា) | SCS Global Consulting (Cambodia) Co., Ltd | ០០៩០ សសរ ក.ជ.គ. | ៣០-មិថុនា-២០២២ |
| ១៦ | អេចធី & ភី ផាតនើរ ឯ.ក | HT & P Partners Co., Ltd | ០០៧៣ សសរ ក.ជ.គ. | ១១-មិថុនា-២០២២ |
| ១៧ | ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី | Deloitte (Cambodia) Co., Ltd | ០០៧៤ សសរ ក.ជ.គ. | ៣០-មេសា-២០២២ |
| ១៨ | វី ឆាធើរ អ៊ីខោនថិន | V Chartered Accountants Co., Ltd | ០០៨៤ សសរ ក.ជ.គ. | ១០-មេសា-២០២២ |
| ១៩ | អ៊ីផឡូ អ៊ិនវេសម៉ិន& ខនសាល់ធីង ឯ.ក | Apollo Investment & Consulting Co., Ltd | ០៧០ សសរ ក.ជ.គ. | ៣១-មីនា-២០២២ |
| ២០ | ម៉ូរីសុនកាក់ អិមខេអេអឌីតអ៊ីខោនធីង ឯក | Morisonkak MKA audit-accounting Co., Ltd | ០០៧២ សសរ ក.ជ.គ. | ៣១-មីនា-២០២២ |
| ២១ | ចន្ទ & អ៊ីសូស៊ីអេត | Chan & Associates Co., Ltd | ០០១៤៧ សសរ ក.ជ.គ. | ២៨-កុម្ភៈ-២០២២ |
| ២២ | អាល់នីសុន អឌីធីង អេន ខនសាល់ធីង | Allnison Auditing and Consulting Co., Ltd | ០០១១៤ សសរ ក.ជ.គ. | ២៨-កុម្ភៈ-២០២២ |
| ២៣ | ប្រាយវ៉តធ័រ ហោវខូភើស៍ (ខេមបូឌា) | PricewaterhouseCoopers (Cambodia) Ltd | ០០៦៣ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ២៤ | ខេ ភី អឹម ជី ខេមបូឌា | KPMG Cambodia Ltd | ០០៦៥ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ២៥ | ហ្វីដេស សឺវីស (ខេមបូឌា) លីមីធីត | FIDES Services Cambodia Ltd | ០០១២៦ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ២៦ | អិន អេ អេស | NAS Co., Ltd | ០០៦២ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ២៧ | អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) | Ernst &Young (Cambodia) Ltd | ០០៦៨ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ២៨ | វូរី អេខោនធីង ខូ អិលធីឌី | Woori Accounting Co., Ltd | ០០១៣៥ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ២៩ | រ៉ូសូខូ លីមីធីត | Rosoco Ltd | ០០៦៩ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣០ | អិលអរអេស ហេនឌើសិន (ខេមបូឌា) | LRS Henderson (Cambodia) Co., Ltd | ០០៨០ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣១ | ដូណាស្កូ & ខមភេនី អិលធីឌី | Donasco & Company., Ltd | ០០១៤២ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |

| | | | | |
|---|---|---|---|---|
| ៣២ | បេក ឃើរ ធីលលី (ខេមបូឌា) ឯ.ក | Baker Tilly Cambodia Co., Ltd | ០០៨៦ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣៣ | ក្រូវ (ខេអេច) ឯ.ក | Crowe (KH) Co., Ltd | ០០១១២ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣៤ | រីនដា អិល អិល ខេ ជី (ខេមបូឌា) | Reanda LLKG (Cambodia) Co., Ltd | ០០១៣៣ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣៥ | ប៊ី ឌី អូ (ខេមបូឌា) លីមីធីត | BDO (Cambodia) Limited | ០០៩៣ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣៦ | អេនឌ្រូ & ហ្វីលីព អីខោនធីង | Andrew & Philip Accounting Co., Ltd | ០០១១៦ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣៧ | ខូវេណិនថ៍ អិលធីឌី | Covenant Ltd | ០០១៣៨ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣៨ | ប៊ីជី អាសូស៊ីអ៊ីត | BG Associates Ltd | ០០៧៦ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៣៩ | អេភីវី (ខេមបូឌា) ខូ អិលធីឌី | APV (Cambodia) Co., Ltd | ០០១០៣ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៤០ | អេធី & អាសូស៊ីអេត | AT & Associates | ០០៦៧ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៤១ | ហ្គ្រេនសនថុន(ខេមបូឌា) លីមីធីត | Grant Thornton (Cambodia) Ltd | ០០១០៨ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៤២ | ខេ ប្រូហ្វេសិនណល អីខោនថិន | K Professional Accountants Co., Ltd | ០០៦១ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៤៣ | សឡូម៉ុនអីខោនធីង& ខនសាល់ធីង | Solomon Accounting & Consulting Co., Ltd | ០០៨២ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៤៤ | អេហ្វអាយអាយ & អឹសូស៊ីអេត | Fii & Associates Co., Ltd | ០០៧១ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៤៥ | ឡូចន្ទ & ខូ (ខេមបូឌា) ឯ.ក | Lochan & Co (Cambodia) Company Limited | ០០១០៦ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |
| ៤៦ | ថៃ អេន ឡោ មេនេចម៉ិន ខនសាល់ធេន ឯក | Thai and Lor Management Consultant Co., Ltd | ០០៦៤ សសរ ក.ជ.គ. | ៣១-ធ្នូ-២០២១ |

**<u>បញ្ជាក់÷</u>**

១. ក្រុមហ៊ុនក្នុងចំណុច I ខាងលើ ពុំមានសិទ្ធិផ្តល់សេវាវិជ្ជាជីវៈសវនកម្មឡើយ។

២. ក្រុមហ៊ុនក្នុងចំណុច II ខាងលើ មានសិទ្ធិជាស្វ័យប្រវត្តិក្នុងការផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ។

៣. ក្រុមហ៊ុនគណនេយ្យ ឬ សវនកម្ម ទាំងឡាយណាដែលពុំមានអាជ្ញាបណ្ណពី និយ័តករគណនេយ្យនិងសវនកម្ម ត្រូវបានហាមឃាត់ក្នុងការផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ ឬ/និង សវនកម្ម។

និយ័តករគណនេយ្យនិងសវនកម្មនឹងធ្វើបច្ចុប្បន្នភាពឈ្មោះក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យ និងក្រុមហ៊ុនសវនកម្ម ជាបន្តបន្ទាប់ជូនម្ចាស់សហគ្រាសប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនដើម្បីជ្រាបជាព័ត៌មាន។

សម្រាប់ព័ត៌មានបន្ថែម សូមអញ្ជើញមកកាន់ទីស្នាក់ការ និយ័តករគណនេយ្យនិងសវនកម្ម ដែលមានអាសយដ្ឋានស្ថិតនៅផ្លូវ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ អគារ (ក )ជាន់ទី១ (ក្នុងបរិវេណទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ឬ ទាក់ទងតាមទូរស័ព្ទលេខ ០៧៧ ៩៦៨ ៣៩៦ ។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់ និយ័តករគណនេយ្យនិងសវនកម្ម